ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣✳៣

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១០៧៧ អក
ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ: **១៣៥ (ឥ)**
ចុះថ្ងៃចន្ទ ៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ០០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្ដាល

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

## មេធាវីការពារក្ដីឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

លោក [redacted] ជាមេធាវីការពារក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងគា

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោក [redacted] ការពារសិទ្ធិឱ្យឈ្មោះ [redacted] សម្បត្តិ

-ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ **១០៧៧ អក** ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងឡាន មានទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ងៀប (រស់) ម្ដាយឈ្មោះ [redacted] សុខ (រស់) ប្រពន្ធឈ្មោះ [redacted] សុខា មានកូនចំនួន ០៣នាក់ ជាទីពឹងជន ទោសពីមុន៖ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៧៣២ ដកបឃខ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ត្រូវចោទពីបទ៖ **ហិង្សាដោយចេតនា និងគំរាមកំហែងហែកហេក្ដី** ប្រព្រឹត្តនៅភូមិដីថ្មី សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **២១៧**, មាត្រា **៣៧២** និងមាត្រា **៣៧៣** នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងគា ភេទស្រី អាយុ២៩ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិសុណនចៃ ឃុំក្រាំងស្វាយ ស្រុកព្រះស្ដេច ខេត្តព្រៃវែង។

-**បានឃើញ** ពាក្យបណ្ដឹង ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ វ៉ា សេងគា ។

-**បានឃើញ** របាយការណ៍សរុបលេខ ០៩៩ របក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ ៨៥១ ដក.សស/២២ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៣៥៤ ដក.សព/២២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖ ១៣៥៩ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

-**បានឃើញ** ដីកាបង្គាប់ឱ្យរក្សាទុកជនត្រូវចោទនៅក្នុងឃុំបណ្ដោះអាសន្នលេខ៖ ១៥៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

## អង្គហេតុនៃរឿងមានដូចតទៅ:

កាលពីថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted] សេងគា ភេទស្រី អាយុ២៩ឆ្នាំត្រូវបានឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ៤២ឆ្នាំ លួងលោមរហូតដល់បានរួមរស់ជាមួយគ្នាដូចជាប្ដីប្រពន្ធ។ ក្រោយមកការរស់នៅមិនចុះសម្រុងនឹងគ្នា ចេះតែឈ្លោះប្រកែកគ្នារហូតដល់ឈ្មោះ [redacted] សម្បត្តិ ចេះតែរករឿងចោទប្រកាន់ឈ្មោះ [redacted] សេងគា ថា មានប្រុសថ្មី ហើយរករឿងរហូតដល់មានការប្រើហិង្សាវាយតប់ទៅលើឈ្មោះ [redacted] សេងគា ទៀតផង។ ក្រោយមកឈ្មោះ [redacted] សេងគា ក៏បានសុំចែកផ្លូវគ្នា តែឈ្មោះ [redacted] សម្បត្តិ មិនព្រម ហើយឈ្មោះ [redacted] សម្បត្តិ បានវាយធ្វើបាប និងគំរាមចែកចាយរូបភាពអាសអាភាស នៅពេលដែលឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សេងគា រួមភេទជាមួយគ្នាទៀតផង។ រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សេងគា ក៏បានទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលគោកឃ្លាំង ហើយសមត្ថកិច្ច ក៏បានហៅឈ្មោះ [redacted] សម្បត្តិ ធ្វើការអប់រំមិនឱ្យប្រើអំពើហិង្សាទៀតទេ។ លុះនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សម្បត្តិ បានផ្ញើរូបភាព ដែលបានថតនៅពេលរួមភេទនោះ ចូលទៅក្នុង តេឡេក្រាម (Telegram) របស់ឈ្មោះ [redacted] សេងគា ហើយឈ្មោះ [redacted] សម្បត្តិ បាននិយាយគំរាមទៀតថា បើបែកផ្លូវគ្នាមែននោះ ឈ្មោះ [redacted] សម្បត្តិ នឹងយករូបភាព ដែលបានថតនៅពេលរួមភេទនោះ ទៅផ្សព្វផ្សាយនៅក្នុងសង្គមហ្វេសបុក(Facebook)។ លុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សេងគា ក៏បានទៅដាក់ពាក្យបណ្ដឹងនៅអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ឱ្យជួយអន្តរាគមន៍ ហើយកម្លាំងសមត្ថកិច្ច ក៏បានហៅឈ្មោះ [redacted] សម្បត្តិ មកកាន់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ដើម្បីសាកសួរនាំ។ លុះនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ កម្លាំងសមត្ថកិច្ចក៏បានឃាត់ខ្លួនឈ្មោះ [redacted] សម្បត្តិ បញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

១-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា៖ ខ្លួនពិតជាបានរួមរស់ជាមួយឈ្មោះ [redacted] សេងគា ភេទស្រី អាយុ២៩ឆ្នាំ អស់រយៈពេល ០៣ឆ្នាំមកហើយ និងបានជួលបន្ទប់រស់នៅជាមួយគ្នាដូចប្ដី និង



Scanned with CamScanner

ប្រពន្ធ នៅសង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ខ្លួន បានជេរស្តីបន្ទោសទៅលើឈ្មោះ [redacted] សេងគា ដោយសារគាត់បានដើរលេងខាងក្រៅច្រើនពេក មានប្រុសថ្មី ហើយខ្លួនបានណែនាំគាត់ជាច្រើនលើក ច្រើនសារមកហើយ តែឈ្មោះ [redacted] សេងគា មិនស្តាប់ខ្លួននោះទេ។ នៅថ្ងៃមួយ ឈ្មោះ [redacted] សេងគា បានរួមភេទជាមួយខ្លួន ហើយឈ្មោះ [redacted] សេងគា បានឱ្យខ្លួនថតសកម្មភាព រួមភេទទុកមើល នៅពេលខ្លួនមិនបាននៅជិតគាត់ ហើយការថតរូបភាពពេលរួមភេទនេះ គឺខ្លួន និងឈ្មោះ [redacted] សេងគា បានព្រមព្រៀងគ្នា។ ហើយការរស់នៅជាមួយគ្នា គឺមានការឈ្លោះប្រកែកគ្នារហូត អំពីរឿង ឈ្មោះ [redacted] សេងគា លួចមានប្រុសថ្មីផិតក្បត់ខ្លួន។ លុះមកដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សេងគា បានណាត់ខ្លួនដើម្បីចចារគ្នា ហើងបងប្រុសរបស់ឈ្មោះ [redacted] សេងគា បានវាយខ្លួនបណ្តាលឱ្យជ្រុះបាត់ ទូរស័ព្ទ ហើយបងប្រុសរបស់ឈ្មោះ [redacted] សេងគា បានវាយទ្រូងខ្លួនបណ្តាលឱ្យឈឺពេញខ្លួន ហើយក៏មាន សមត្ថកិច្ចបានចុះមកជួយអន្តរាគមន៍ យកខ្លួនមកកាន់អធិការដ្ឋាននគរបាល ស្រុកកៀនស្វាយ ដើម្បីសាកសួរនាំ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងគា** បានឆ្លើយថា៖ នៅថ្ងៃខែមិនចាំ ឆ្នាំ២០១៥ ខ្លួន បាន ស្គាល់ឈ្មោះ [redacted] សម្បត្តិ រហូតដល់ថ្ងៃខែមិនចាំ ឆ្នាំ២០១៧ ឈ្មោះ [redacted] សម្បត្តិ បានលួងលោមខ្លួន សុំស្រលាញ់ខ្លួនធ្វើជាប្រពន្ធ និងសន្យារៀបការជាមួយគ្នាស្របច្បាប់ ទិញផ្ទះ ទិញឡាន ឱ្យខ្លួន។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ខ្លួនបានមកនៅបន្ទប់ជួលនៅសង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមួយ ឈ្មោះ [redacted] សម្បត្តិ ដូចជាប្តី និងប្រពន្ធ ដោយមិនបានឈ្លោះប្រកែកគ្នានោះទេ។ នៅថ្ងៃមិនចាំ ខែកុម្ភៈ ឆ្នាំ២០២២ ខ្លួនបានសុំបែកគ្នាជាមួយឈ្មោះ [redacted] សម្បត្តិ តែឈ្មោះ [redacted] សម្បត្តិ មិនព្រម ហើយឈ្មោះ គា សម្បត្តិ បានប្រើអំពើហិង្សាមកលើខ្លួនដោយវាយខ្លួន និងយកខ្សែក្រវ៉ាត់វាយខ្លួនទៀតផង។ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ [redacted] សម្បត្តិ បាននិយាយគំរាមបង្ហោះរូបភាពនៅក្នុងបណ្តាញសង្គមហ្វេសបុក ដោយបាននិយាយថា បើហ៊ានបែកគ្នា គេនិងសម្លាប់ខ្លួន កាត់ដៃ កាត់ជើង ដាក់ក្នុងទូរទឹកកក។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ខ្លួន និងឈ្មោះ [redacted] សម្បត្តិ បានមកប៉ុស្តិ៍នគរបាលរដ្ឋបាលគោកឃ្លាំង ដើម្បីធ្វើកិច្ចសន្យាចែកផ្លូវគ្នារៀងៗខ្លួន និងមិនចែកចាយរូបភាពអាសអាភាស។ លុះដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សម្បត្តិ បានផ្ញើវីដេអូរ ខ្លួនធ្លាប់រួមភេទជាមួយឈ្មោះ [redacted] សម្បត្តិ មកឱ្យខ្លួនតាមហ្វេសបុករបស់ខ្លួន និងនិយាយគំរាមបង្ហោះរូបភាពនោះ។ នៅពេលខ្លួនរួមរស់នៅជាមួយឈ្មោះ [redacted] សម្បត្តិ គឺឈ្មោះ [redacted] សម្បត្តិ បានឱ្យខ្លួនបៀមប្រដាប់ភេទ ឱ្យខ្លួននៅពីលើ និងធ្វើតាមអ្វីដែល គាត់ចង់។ ហើយចំពោះវីដេអូរនោះ គឺខ្លួនមិនដឹងថាថតនៅពេលណានោះទេ។

៣-សាក្សីឈ្មោះ [redacted] **សំខាន់** បានឆ្លើយបំភ្លឺថា៖ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ឈ្មោះ តាម៉ាប់ បាន មកជួលបន្ទប់នៅសង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយបានរស់នៅអស់រយៈពេលបួនឆ្នាំ មកហើយ។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ តាម៉ាប់ បានឈ្លោះប្រកែកគ្នាជាមួយប្រពន្ធរបស់គាត់ នៅក្នុងផ្ទះជួល តែឈ្មោះ តាម៉ាប់ មិនបានប្រើហិង្សានោះទេ។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ តាម៉ាប់ បានឈ្លោះប្រកែកគ្នាជាមួយប្រពន្ធរបស់គាត់នៅក្នុងផ្ទះជួល តែឈ្មោះ តាម៉ាប់ មិនបានប្រើហិង្សា នោះដែរ។ លុះវេលាម៉ោង ១៧ និង ៣០ នាទី ខ្លួនឃើញឈ្មោះ តាម៉ាប់ ស្រែក ឡូឡាដាក់ប្រពន្ធរបស់គាត់ ហើយឈ្មោះ តាម៉ាប់ បានទះកំភ្លៀងប្រពន្ធគាត់ និងចាប់បោចសក់ បន្ទាប់មកខ្លួនក៏បានចូលទៅឃាត់បំបែក ចេញ។ បានមួយសន្ទុះក្រោយមក សមត្ថកិច្ចក៏បានមកដល់ ហើយហៅឈ្មោះ តាម៉ាប់ ទៅកាន់ប៉ុស្តិ៍នគបាល រដ្ឋបាលគោកឃ្លាំង ដើម្បីសាកសួរ។



Scanned with CamScanner

៤-សាក្សីឈ្មោះ [redacted] **សុខា** បានឆ្លើយបំភ្លឺថា៖ ខ្លួនបានរៀបការជាមួយឈ្មោះ [redacted] សម្បត្តិ នៅឆ្នាំ២០០១ ដោយមានកូនចំនួន ០៣នាក់ ស្រី០១នាក់ និងប្រុស ០២នាក់។ នៅឆ្នាំ២០១៦ ខ្លួនបានដឹងថាប្តីខ្លួនឈ្មោះ [redacted] សម្បត្តិ បានលួចទាក់ទងជាមួយស្រីខាងក្រៅឈ្មោះ [redacted] សេងគា ហើយក្រោយពីប្តីខ្លួនឈ្មោះ [redacted] សម្បត្តិ លួចមានស្រីខាងក្រៅមក គឺគាត់តែងតែរករឿងខ្លួនរហូតមកដល់សព្វថ្ងៃ។ រហូតដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ ទើបគាត់បានប្រាប់ខ្លួនថា គាត់មានស្រីខាងក្រៅ។

៥-លោក [redacted] មេធាវីការពារក្តីឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ផ្អែកតាមអង្គហេតុ អង្គច្បាប់ ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងក្នុងសំណុំរឿង សបញ្ជាក់ឱ្យឃើញថា: ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពិតជាបានប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនា និងគំរាមកំហែងហែកកេរ្តិ៍ មកលើកូនក្តីខ្លួនពិតប្រាកដមែន ហេតុនេះ ស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានធ្ងន់ធ្ងរនិងសម្រេចឱ្យជនជាប់ចោទសងសំណងជូនដូចការទាមទាររបស់ដើមបណ្តឹង។

៦-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ។ ព្រោះថាពុំមានភស្តុតាងដាក់បន្ទុក និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ឡើយ និងស្នើសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន និងសម្រេចដោះលែងឱ្យមានសេរីភាពឡើងវិញ។

៧-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយជនជាប់ចោទ និងអំណានចម្លើយបំភ្លឺសាក្សី ព្រមទាំងវត្ថុតាងនានានៅក្នុងសំណុំរឿង ឃើញថាមានភាពស៊ីចង្វាក់គ្នាទៅនិងអង្គហេតុ ថាពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនា និងគំរាមកំហែងហែកកេរ្តិ៍** នៅភូមិដីថ្មី សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៤២ ឆ្នាំ ពិតប្រាកដមែន ដែលអំពើនេះបានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **២១៧**, មាត្រា **៣៧២** និងមាត្រា **៣៧៣** នៃក្រមព្រហ្មទណ្ឌ ហេតុនេះរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១៣៥៤ ដក.សព/២២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ទុកដដែល និងសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

៨-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា៖ ស្នើសុំតុលាការជួយសម្រាលទោសដល់រូបខ្លួនផង ដោយសាររូបខ្លួនមានជម្ងឺប្រចាំកាយ និងមានកូនតូចៗត្រូវទទួលបន្ទុក។

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារក្តីឱ្យដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ



Scanned with CamScanner

## សំអាងហេតុ

១-កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted] សេងគា ភេទស្រី អាយុ២៩ឆ្នាំត្រូវបាន ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ៤២ឆ្នាំ លួងលោមរហូតដល់បានរួមរស់ជាមួយគ្នាដូចជាប្តីប្រពន្ធ ពិតជាមានអង្គហេតុដែលជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានប្រើហិង្សាដោយចេតនា និងគំរាមកំហែងហែកេរ្តិ៍ ដែលប្រព្រឹត្តនៅភូមិដីថ្មី សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទីទី២៣ ខែកក្កដា ឆ្នាំ២០២២ ពិតប្រាកដមែន។ ក្រោយមកឈ្មោះ [redacted] សេងគា ក៏បានសុំចែកផ្លូវគ្នា តែឈ្មោះ [redacted] សម្បត្តិ មិនព្រម ហើយឈ្មោះ [redacted] សម្បត្តិ បានវាយធ្វើបាប និងគំរាមចែកចាយរូបភាពអាសអាភាស នៅពេលដែលឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សេងគា រួមភេទជាមួយគ្នាទៀតផង។ រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សេងគា ក៏បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលគោកឃ្លាំង ហើយសមត្ថកិច្ច ក៏បានហៅឈ្មោះ [redacted] សម្បត្តិ ធ្វើការអប់រំមិនឱ្យប្រើអំពើហិង្សាទៀតទេ។ លុះនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សម្បត្តិ បានផ្ញើរូបភាព ដែលបានថតនៅពេលរួមភេទនោះ ចូលទៅក្នុង តេឡេក្រាម(Telegram) របស់ឈ្មោះ [redacted] សេងគា ហើយឈ្មោះ [redacted] សម្បត្តិ បាននិយាយគំរាមទៀតថា បើបែកផ្លូវគ្នាមែននោះ ឈ្មោះ [redacted] សម្បត្តិ នឹងយករូបភាព ដែលបានថតនៅពេលរួមភេទនោះ ទៅផ្សព្វផ្សាយនៅក្នុងសង្គមហ្វេសបុក (Facebook)។ លុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សេងគា ក៏បានទៅដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ឱ្យជួយអន្តរាគមន៍ ហើយកម្លាំងសមត្ថកិច្ច ក៏បានហៅឈ្មោះ គា សម្បត្តិ មកកាន់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ដើម្បីសាកសួរនាំ។

២-តំណាងអយ្យការបានចោទប្រកាន់ឈ្មោះ [redacted] **សម្បត្តិ** ពីបទ **ហិង្សាដោយចេតនា និងគំរាមកំហែងហែកេរ្តិ៍**។ ជូនមកចៅក្រមស៊ើបសួរ និងក្រោយពីបានបំពេញកិច្ចស៊ើបសួរចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរក៏បានបញ្ជូនរឿងមកជំនុំជម្រះតាមការប្តឹងចោទប្រកាន់របស់តំណាងអយ្យការ។

៣-ផ្អែកលើចម្លើយរបស់សាក្សីដាក់បន្ទុកដែលបានឆ្លើយបំភ្លឺនៅតុលាការ គឺជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពិតជាបានឈ្លោះប្រកែកគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងគា ហើយបានទះកំភ្លៀងទៅលើឈ្មោះ [redacted] សេងគា និងចាប់បោចសក់ទៀតផង។

៤-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ បានសារភាពថា នៅពេលកើតហេតុ ខ្លួន និងឈ្មោះ [redacted] **សេងគា** បានឈ្លោះប្រកែកគ្នា ដោយឈ្មោះ [redacted] **សេងគា** បានលួចមានប្រុសថ្មីហើយខ្លួនបានជេរទៅលើគាត់ និងបានប្រើហិង្សាទៅលើគាត់។ ហើយការរស់នៅជាមួយគ្នា ខ្លួន និងឈ្មោះ [redacted] **សេងគា** បានព្រមព្រៀងគ្នារួមភេទ និងថតវីដេអូរទុកសម្រាប់មើល ដោយឈ្មោះ [redacted] **សេងគា** និយាយថា ទុកមើលពេលខ្លួនមិននៅជិត។

៥-ផ្អែកលើចម្លើយរបស់សាក្សីឈ្មោះ [redacted] **សំខាន់** ពិតជាបានបញ្ជាក់ច្បាស់ថា កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ខ្លួនបានឮសម្លេងឈ្មោះ [redacted] **សម្បត្តិ** ឈ្លោះគ្នាជាមួយឈ្មោះ [redacted] **សេងគា** ហើយឈ្មោះ [redacted] **សម្បត្តិ** បានទះកំភ្លៀងទៅលើឈ្មោះ [redacted] **សេងគា** និងចាប់បោចសក់ទៀតផង បន្ទាប់មកខ្លួនក៏បានចូលទៅចាប់ឃាត់បំបែក។

៦-ផ្អែកលើវេជ្ជបញ្ជាពេទ្យ និងលទ្ធផលមន្ទីរពិសោធន៍វេជ្ជសាស្ត្របានបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** ពិតជាមានបញ្ហាសុខភាព ពិតប្រាកដមែន។

៧-តាមរបាយការណ៍លេខ ០៩៩ របក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ បានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** បានប្រព្រឹត្តបទល្មើស ប្រើ



Scanned with CamScanner

**ហិង្សាដោយចេតនា និងការផលិតគំរាមផ្សាយរូបភាពអាសអាភាស** ទៅជនរងគ្រោះឈ្មោះ [redacted] សេងគា កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ ពិតប្រាកដមែន។

៨-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន៖ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឱ្យចៅក្រមជំនុំជម្រះផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

៩-មេធាវីការពារក្ដីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋាន៖ សុំអោយតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ និងសម្រេចអោយជនជាប់ចោទសងសំណងជូចការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន៖ សុំអោយតុលាការផ្ដល់ស្ថានសម្រាលទោសដល់កូនក្ដីខ្លួន និងសម្រេចដោះលែងឱ្យមានសេរីភាពឡើងវិញ។

១១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ៤២ឆ្នាំ ពីបទ៖ **ហិង្សាដោយចេតនា និងគំរាមកំហែងហែកកេរ្ដិ៍** ប្រព្រឹត្តនៅភូមិដីថ្មី សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **២១៧**, មាត្រា **៣៧២** និងមាត្រា **៣៧៣** នៃក្រមព្រហ្មទណ្ឌ។

១២-ជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** បានសារភាពកំហុសរបស់ខ្លួន ដោយមូលហេតុជនជាប់ចោទមានបញ្ហាសុខភាព ពិតប្រាកដមែន ដូច្នេះហើយជនជាប់ចោទរូបនេះ ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង និងពុំបានបង្កឱ្យមានព្យសនៈកម្មធ្ងន់ធ្ងរដល់ជនរងគ្រោះនោះទេ និងស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបគេ ដើម្បីអាចកែខ្លួនជាពលរដ្ឋល្អឡើងវិញ ហេតុដូច្នេះគប្បីតុលាការពិចារណាសម្រេចអំពីស្ថានសម្រាលទោស ដល់ជនជាប់ចោទរូបនេះ ដើម្បីទុកឱកាសឱ្យគេកែប្រែខ្លួនធ្វើជាពលរដ្ឋល្អជាថ្មី គប្បីតុលាការផ្ដល់ស្ថានសម្រាលទោសតាមមាត្រា **១០៨** នៃក្រមព្រហ្មទណ្ឌ។

១៣-**វត្ថុតាងចាប់យករួមមាន:**

ក-ទូរស័ព្ទ ០១គ្រឿង ម៉ាក Iphone ពណ៌ខ្មៅ (បែកខាងមុខមិនប្រក្រតី)

ខ-លោហធាតុពណ៌លឿង ប្រវែងប្រហែល ២៨ សង់ទីម៉ែត្រចំនួន ២ខ្សែរ។

គ-លោហធាតុទឹកប្រាក់ប្រវែងប្រហែល ០,៨៤ម៉ែត្រ មានត្បូត ១២គ្រាប់ ចំនួន ០១ខ្សែរ។

ឃ-ឡែបថបម៉ាក Acer ពណ៌ខ្មៅ ចំនួន ០១ និងខ្សែរសាកថ្មឡែបថបចំនួនមួយ។

ង-កាបូប Lyuess ពណ៌ខ្មៅ ចំនួន ០១។

តុលាការគប្បីពិចារណា និងសម្រេចទៅតាមច្បាប់ ។

១៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងគា** បានប្ដឹងទាមទារជម្ងឺចិត្តចំនួន **១០០.០០០.០០០៛(មួយរយលាន)រៀល** ពីជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** ។ គប្បីតុលាការពិចារណា និងសម្រេចទៅតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

**១-ផ្ដន្ទាទោស៖** ជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ៤២ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ០៤(បួន)ខែ ១៥(ដប់ប្រាំ)ថ្ងៃ **ទោសសល់ពីនេះត្រូវព្យួរសាកល្បងកំណត់រយៈពេល** ០៣(បី)។



Scanned with CamScanner

ពីបទ៖ ហិង្សាដោយចេតនា និងគំរាមកំហែងហែតកេរ្ត៍ ប្រព្រឹត្តនៅប្រព្រឹត្តនៅភូមិដីថ្មី សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧, មាត្រា ៣៧២, មាត្រា ៣៧៣ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ សងសំណងខូចខាតនិងជំងឺចិត្តចំនួន ៦០.០០០.០០០៛ (ហុកសិបលាន)រៀល អោយទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងគា សំណូមពរលើសពីនេះបដិសេធចោល ។

៣-វត្ថុតាងចាប់យកដែលត្រូវប្រគល់ឱ្យម្ចាស់ដើមវិញរួមមាន៖ ទូរស័ព្ទ ០១គ្រឿង ម៉ាក Iphone ពណ៌ខ្មៅ (បែកខាងមុខមិនប្រក្រតី), លោហធាតុពណ៌លឿង ប្រវែងប្រហែល ២៨ សង់ទីម៉ែត្រចំនួន ២ខ្សែរ, លោហធាតុទឹកប្រាក់ប្រវែងប្រហែល ០,៨៤ម៉ែត្រ មានឡូត ១២គ្រាប់ ចំនួន ០១ខ្សែរ, ឡែបថបម៉ាក Acer ពណ៌ខ្មៅ ចំនួន ០១ និងខ្សែរសាកថ្មឡែបថបចំនួនមួយ និងកាបូប Lyuess ពណ៌ខ្មៅ ចំនួន ០១។

សាលក្រមនេះជំនុំជម្រះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងគា និងប្រកាសជាសាធារណៈនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម
ថ្ងៃចន្ទ ៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កណ្តាល, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner